Inter-Parliamentary Union
For democracy. For everyone.

# កម្ពុជា

CMBD/២៧ - ចាន់ ចេង

CMBD/៤៨ - លោកស្រី មូរ សុខហួរ

CMBD/៤៩ - កែវ ភីរម្យ

CMBD/៥០ - ហូ វ៉ាន់

CMBD/៥១ - ឡុង រី

CMBD/៥២ - នុត រំដួល

CMBD/៥៣ - ម៉ែន សុថាវរិន

CMBD/៥៤ - រៀល ខេមរិន្ទ

CMBD/៥៥ - ហុង សុខហួរ

CMBD/៥៦ - គង់ សភា

CMBD/៥៧ - ញ៉យ ចំរើន

CMBD/៥៨ - សម រង្ស៊ី

## សេចក្តីសម្រេចអនុម័តជាឯកច្ឆ័នដោយក្រុមប្រឹក្សាអភិបាលនៃសហភាពអន្តរសភា(IPU) នាសម័យប្រជុំលើកទី១៩៨ (ទីក្រុងលូសាកា ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦)[1]

ក្រុមប្រឹក្សាអភិបាលនៃសហភាពអន្តរសភា(IPU)

យោងទៅលើសំណុំរឿងក្តីចំនួនប្រាំ ដែលបានដាក់ជូនគណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាជិកសភា ទាក់ទងនឹងសមាជិកសភាចំនួន ១២ រូបដែលមកពីគណបក្សសង្គ្រោះជាតិ (CNRP) រួមមាន (១) លោក ចាន់ ចេង (២) លោកស្រី មូរ សុខហួរ លោក កែវ ភីរម្យ លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវរិន និងលោក រៀល ខេមរិន្ទ (៣) លោក ហុង សុខហួរ (៤) លោក គង់ សភា និង លោក ញ៉យ ចំរើន និង (៥) លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំង

[1] គណៈប្រតិភូកម្ពុជា បានសម្តែងខរក្សាទុករបស់ខ្លួន ចំពោះសេចក្តីសម្រេចនេះ។

និងដែលត្រូវបានរក្សាជាការសម្ងាត់ អនុលោមតាមផ្នែកទី ២២(១) នៃវិធាន និងការអនុវត្តរបស់គណៈកម្មាធិការទទួលបន្ទុកសិទ្ធិមនុស្សរបស់សមាជិកសភា និងនិតិវិធីរបស់ខ្លួនសម្រាប់ការពិនិត្យ និងចាត់ការពាក្យបណ្ដឹងមួយៗដាច់ដោយឡែកពីគ្នា ចាប់តាំងពីឆ្នាំ២០១១ (i) ឆ្នាំ២០១៤ (ii) និងឆ្នាំ២០១៥ (iii, iv និង v)

ដោយពិចារណាលើព័ត៌មានដូចខាងក្រោម នៅលើសំណុំរឿង៖

- លោក ចាន់ ចេង ជាសមាជិកមួយរូបនៃរដ្ឋសភា ត្រូវបានតុលាការផ្ដន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេលពីរឆ្នាំ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៥ បន្ទាប់ពីដំណើរការមានភាពស្ងប់ស្ងាត់មួយរយៈពេលវែងមក ដែលគេជឿជាក់ថាត្រូវបានលើកលែងចោទប្រកាន់នៅឆ្នាំ២០១២ ប៉ុន្តែភ្លាមៗក៏ស្រាប់ដំណើរការជាថ្មីឡើងវិញ នៅពាក់កណ្ដាលឆ្នាំ ២០១៤ នៅខណៈពេលដែលមានការជាប់គាំងនយោបាយដ៏តានតឹងរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង។ លោក ចាន់ចេង បានប្ដឹងឧទ្ធរណ៍លើសេចក្ដីសម្រេចរបស់តុលាការនេះ ដែលបណ្ដឹងឧទ្ធរណ៍កំពុងរង់ចាំការជំនុំជម្រះនៅឡើយ។ លោកមានសេរីភាព និងអាចអនុវត្តអាណត្តិសភារបស់លោកដូចធម្មតា។

- លោកស្រី មូរ សុខហួរ លោក កែវ ភីរម្យ លោក ហូ វ៉ាន់ លោក ឡុង រី លោក នុត រំដួល លោក ម៉ែន សុថាវរិន និងលោក រៀល ខេមរិន្ទ ទាំងអស់គ្នាគឺជាសមាជិកសភា ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ ជាមួយនឹងសកម្មជនគណបក្សប្រឆាំងផ្សេងទៀត បន្ទាប់ពីមានបាតុកម្មមួយ អំពាវឲ្យបើកឡើងវិញនូវទីលានតវ៉ាមួយកន្លែងនៅរាជធានីភ្នំពេញ គេស្គាល់ថាជាសួនសេរីភាព (ឬទីលានប្រជាធិបតេយ្យ) បានក្លាយទៅជាអំពើហឹង្សា។ ពួកគេ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ ចោទប្រកាន់ពីបទដឹកនាំកុបកម្ម ប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស និងញុះញង់ឲ្យអ្នកដទៃប្រព្រឹត្តបទល្មើស ហើយដែលត្រូវប្រឈមនឹងទោសជាប់ពន្ធនាគាររហូតដល់៣០ ឆ្នាំ។ ពួកគេ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយមានលក្ខខណ្ឌនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៤ បន្ទាប់ពីមានការប្រកាសអំពីកិច្ចព្រមព្រៀងនយោបាយមួយរវាងរដ្ឋាភិបាល និងគណបក្សប្រឆាំង ដើម្បីបញ្ចប់វិបត្តិនយោបាយ។ ការស៊ើបសួរនៅតែបន្ត និងមិនទាន់មានការកំណត់កាលបរិច្ឆេទសម្រាប់ការជំនុំជម្រះសមាជិកសភាទាំងនេះនៅឡើយទេ។ ពួកគេមានសេរីភាព និងអាចអនុវត្តអាណត្តិសភារបស់ខ្លួនដូចធម្មតា។

- លោក ហុង សុខហួរ ជាសមាជិកព្រឹទ្ធសភា ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ បន្ទាប់ពីមានខ្សែវីដេអូឃ្លីបមួយ ត្រូវបានបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់មេដឹកនាំគណបក្សប្រឆាំងគឺលោកសម រង្ស៊ី នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។ ខ្សែវីដេអូឃ្លីបនេះ បានបង្ហាញរូបភាពរបស់លោក ហុង សុខហួរ សំដែងទស្សនៈរបស់គាត់អំពីបញ្ហាព្រំដែនវៀតណាម-កម្ពុជា ដែលជាបញ្ហាមួយដ៏ចម្រូងចម្រាស់ និងរសើបនៅក្នុងកម្ពុជា និងបង្ហាញច្បាប់ចម្លងនៃអត្ថបទសន្ធិសញ្ញាព្រំដែនវៀតណាម-កម្ពុជា ឆ្នាំ១៩៧៩ ដែលនិយាយថាព្រំដែននឹងត្រូវរំលាយ និងធ្វើការកំណត់ឡើងវិញ ដែលបានបង្ហាញពីភាពមិនត្រឹមត្រូវ។

នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៥ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចោទប្រកាន់សមាជិកព្រឹទ្ធសភារូបនេះ ថាក្បត់ជាតិ និងបានបញ្ជាឲ្យចាប់ខ្លួនលោក។ ក្រោយមក សមាជិកព្រឹទ្ធសភារូបនេះ ត្រូវបានឃុំខ្លួននៅ ថ្ងៃទី១៥ សីហា ឆ្នាំ២០១៥ និងត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំឯកសារសាធារណៈ ដោយប្រើឯកសារសាធារណៈក្លែងក្លាយ និងញុះញង់ឲ្យមានចលាចលក្នុងសង្គម។ គាត់អាចទទួលរងទោសជាប់ពន្ធនាគាររហូតដល់ទៅ១៧ ឆ្នាំ។ អភ័យឯកសិទ្ធិរបស់លោក មិនត្រូវបានដកហូតទេ ដោយសារអាជ្ញាធរបានចាត់ទុកថា លោកត្រូវបានចាប់ខ្លួនក្នុងការប្រព្រឹត្តបទលើសជាក់ស្តែង។ លោកស្ថិតនៅក្នុងការឃុំខ្លួននៅឡើយ ដោយសារការស្នើសុំនៅក្រៅឃុំរបស់លោក ត្រូវបានបដិសេធជាលក្ខណៈប្រព័ន្ធដោយតុលាការ។ ការជំនុំជម្រះលើសំណុំរឿងក្តីរបស់លោក បានចាប់ផ្តើមនៅខែតុលាឆ្នាំ២០១៥ ហើយត្រូវបានលើកពេលជាច្រើនលើកច្រើនសារ។

- លោក គង់ សភា និង លោក ញ៉យ ចំរើន ជាសមាជិកសភា ត្រូវបានគេទាញចេញពីរថយន្តរបស់លោក ហើយត្រូវគេវាយដំដោយហិង្សា ខណៈពេលដែលលោកទាំងពីរកំពុងធ្វើដំណើរចាកចេញពីរដ្ឋសភា នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥។ មានបាតុកម្មមួយប្រឆាំងនឹងគណបក្សប្រឆាំង ត្រូវបានរៀបចំឡើងដោយគណបក្សកាន់អំណាច កំពុងធ្វើនៅខាងមុខវិមានរដ្ឋសភា នៅពេលនោះ។ ទាំងមន្ត្រីសន្តិសុខរដ្ឋសភា ទាំងមន្ត្រីនគរបាលមានវត្តមាននៅទីនោះ មិនបានចាត់វិធានការណាមួយ មុនពេល ក្នុងពេល ឬបន្ទាប់ពីការវាយប្រហារនោះឡើយ ដូចដែលបានបង្ហាញនៅលើខ្សែវីដេអូក្លីបនៅកន្លែងកើតហេតុ។ ការវាយប្រហារនេះ បានធ្វើឲ្យសមាជិកទាំងពីររូបនេះរងរបួសយ៉ាងធ្ងន់ធ្ងរ។ ការវាយប្រហារនេះ ត្រូវបានរដ្ឋសភាធ្វើការថ្កោលទោស ហើយការស៊ើបអង្កេតមួយ ត្រូវបានផ្តួចផ្តើមធ្វើ ដែលឈានទៅដល់ការចាប់ខ្លួនជនសង្ស័យចំនួនបីរូប នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៥ ដែលតាមការរាយការណ៍ថា បានធ្វើឡើងបន្ទាប់ពីពួកគេបានឆ្លើយសារភាពថា បានចូលរួមនៅក្នុងអំពើហិង្សានេះ។ ទោះជាយ៉ាងណាក៏ដោយ មិនទាន់មាននរណាត្រូវបានដាក់ឲ្យទទួលខុសត្រូវ ហើយក៏មិនមានវិធានការបន្ថែមណាមួយ ត្រូវបានចាត់ទៅលើអ្នកវាយប្រហារផ្សេងទៀត ឬអ្នកញុះញង់ដែរ ទោះបីជាសាមីសមាជិកសភាបានដាក់ពាក្យបណ្តឹងហើយក្តី និងខ្សែវីដេអូ បានបង្ហាញយ៉ាងច្បាស់ពីសកម្មភាពវាយប្រហារ បង្ហាញអត្តសញ្ញាណរបស់អ្នកវាយប្រហារ និងហេតុការណ៍ជាក់ស្តែងដែលពួកគេបាននិងកំពុងនិយាយទាក់ទងគ្នាជាមួយអ្នកដទៃទៀត តាមរយៈវិទ្យុទាក់ទងក្តី។

- លោក សម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំង និងជាសមាជិកសភាមួយរូប ត្រូវបានគេកំណត់ជាគោលដៅ ដោយករណីរឿងចំនួនបួនដាច់ដោយឡែកពីគ្នា ចន្លោះពីខែវិច្ឆិកា ឆ្នាំ២០១៥ និងខែមករា ឆ្នាំ២០១៦ (រាប់ទាំងករណីរឿងមួយ ដែលទាក់ទងទៅនឹងករណីរបស់សមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ ដែលបង្ហោះវីដេអូឃ្លីបលើទំព័រហ្វេសប៊ុករបស់លោកផងដែរ)។ អភ័យឯកសិទ្ធិរបស់លោក មិនត្រូវបានដកហូតទេ ប៉ុន្តែអាណត្តិសភារបស់គាត់ត្រូវបានដកហូតពាក់ព័ន្ធនឹងករណីរបស់លោកនៅសាលាដំបូង។ លោកត្រូវបានបង្ខំចិត្តធ្វើនិរទេសខ្លួនទៅក្រៅប្រទេស ដើម្បីជៀសវាងការជាប់ពន្ធនាគារ ចាប់ពី

ខែវិច្ឆិកា ឆ្នាំ២០១៥។

*ដោយយល់ឃើញថា* គណៈកម្មាធិការបានសម្រេចតាំងពីដំបូងថា រក្សាករណីសំណុំរឿងទាំងនេះជាការសម្ងាត់ ដើម្បីផ្តល់ឱកាសឲ្យគណបក្សទាំងពីរស្វែងរកដំណោះស្រាយ តាមរយៈការសន្ទនានយោបាយ ព្រោះថាកិច្ចសន្ទនានេះ បានបន្តធ្វើរវាងបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា (CPP) និងគណបក្សសង្គ្រោះជាតិ (CNRP) បន្ទាប់ពីមានកិច្ចព្រមព្រៀងមួយក្នុងខែកក្កដា ឆ្នាំ២០១៤។ កិច្ចព្រមព្រៀងនេះ បានបញ្ចប់វិបត្តិក្រោយការបោះឆ្នោត ឆ្នាំ ២០១៣ និងបានបង្កើតយន្តការសម្រាប់កិច្ចសន្ទនារវាងគណបក្សនយោបាយធំៗទាំងពីរ ដែលមានតំណាងនៅក្នុងរដ្ឋសភា ដែលគេស្គាល់ថាជា "វប្បធម៌សន្ទនា"។ ទន្ទឹមនឹងថ្មី ហើយផុយស្រួយ វប្បធម៌សន្ទនានេះ ត្រូវបានភាគីទាំងពីរមើលឃើញថា មានសារៈសំខាន់ ដើម្បីបញ្ចប់វប្បធម៌ហឹង្សាទូទៅកន្លងមក។ វប្បធម៌នេះបានបើកចំហបន្ថែមទៀតសម្រាប់ការសន្ទនានយោបាយនៅក្នុងស្ថាប័នសភា និងបានអនុញ្ញាតឲ្យភាគីទាំងអស់ សម្រេចបាននូវវឌ្ឍនភាពលើបញ្ហាមួយចំនួនដែលជាផលប្រយោជន៍ជាតិ ចន្លោះពីខែកក្កដា ឆ្នាំ២០១៤ និង នៅពាក់កណ្តាលឆ្នាំ២០១៥។

*ដោយយល់ឃើញថា* គណៈប្រតិភូកម្ពុជានាសម័យប្រជុំសភា IPU លើកទី១៣៣ (ទីក្រុងហ្សឺណែវ ខែតុលា ឆ្នាំ២០១៥) បានស្វាគមន៍សំណើរបស់គណៈកម្មាធិការនេះ ដើម្បីធ្វើដំណើរទស្សនកិច្ចមកកាន់កម្ពុជា ហើយថាដំណើរទស្សនកិច្ចនេះ បានធ្វើឡើងចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៦ ដោយសមាជិករបស់សភា IPU គឺលោក អាលី អេ អាឡារ៉ាឌី (Mr. Ali A. Alaradi) និងលោក អាលីអូនេ អាបាតាលីប ហ្គេយេ (Mr. Alioune Abatalib Gueye)។

*ដោយយល់ឃើញថា* ដំណើរទស្សនកិច្ចនេះមានគោលដៅសំខាន់ចំនួនពីរ៖ ទីមួយ ដើម្បីឲ្យគណៈកម្មាធិការយល់ដឹងច្រើនបន្ថែមទៀតអំពីករណីសំណុំរឿងរបស់តំណាងរាស្ត្រសាមីចំនួន ១២រូប របស់គណបក្សប្រឆាំង និងអំពីបរិបទសិទ្ធិមនុស្ស និងនយោបាយដែលបានកើតឡើង ទីពីរ ដើម្បីជម្រុញឲ្យមានដំណោះស្រាយគួរជាទីគាប់ចិត្ត ក្នុងករណីសំណុំរឿងទាំងនេះផ្ទាល់ ស្របតាមក្របខណ្ឌរដ្ឋធម្មនុញ្ញរបស់កម្ពុជា និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលគណៈកម្មាធិការចាត់ទុកដំណើរទស្សនកិច្ចរបស់ខ្លួនថាជា "ដំណើរទស្សនកិច្ចជាជម្រើសចុងក្រោយ" បន្ទាប់ពីគណៈកម្មាធិការបានផ្តល់ពេលវេលាម្តងហើយម្តងទៀត ឲ្យភាគីទាំងពីរស្វែងរកដំណោះស្រាយតាមរយៈការចរចារ។

*ដោយយល់ឃើញថា* នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្លួន គណៈប្រតិភូបានជួបប្រជុំភាគច្រើនបំផុត ទៅតាមកម្មវិធីដែលបានស្នើសុំ រាប់ទាំងជាមួយអាជ្ញាធរសភា នីតិប្រតិបត្តិ និងតុលាការ គណបក្សនយោបាយធំៗចំនួនពីរ សមាជិកសភាសាមីភាគច្រើន ព្រមទាំងភាគីទីបីដូចជាការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំកម្ពុជា អ្នកការទូតបរទេស និងតំណាងសំខាន់ៗនៃសង្គមស៊ីវិលកម្ពុជា។ *ដោយយល់ឃើញថា* សំណើរបស់គណៈប្រតិភូ ទៅសួរសុខទុក្ខសមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ នៅមណ្ឌលអប់រំកែប្រែព្រៃស ដែលត្រូវបានអនុញ្ញាតជាយថាហេតុនៅថ្ងៃចុងក្រោយនៃដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ។ ហើយ*ដោយយល់ឃើញថា* គណៈប្រតិភូអាចជួបជាមួយលោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងការអវត្តមានរបស់លោកនាយករដ្ឋមន្ត្រី ដែលលោកអញ្ជើញទៅ

ក្រៅប្រទេសដើម្បីចូលរួមក្នុងកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក។

*ដោយយល់ឃើញថា* របាយការណ៍ចុងក្រោយនៃបេសកកម្ម នឹងត្រូវបានជូនក្រុមប្រឹក្សាភិបាល នាសម័យប្រជុំបន្ទាប់របស់ខ្លួន នៅក្នុងអំឡុងពេលនៃសម័យប្រជុំលើកទី១៣៥ របស់សហភាពអន្តរសភា (IPU) (ខែតុលា ឆ្នាំ២០១៦) បន្ទាប់ពីត្រូវបានចែករំលែកជាមួយភាគីទាំងអស់សម្រាប់ការសង្កេតរបស់ខ្លួន ប៉ុន្តែថា គណៈកម្មាធិការនេះ មានបំណងចែករំលែកអនុសាសន៍ និងសេចក្តីសង្កេតបឋមរបស់គណៈប្រតិភូដូចខាងក្រោមនេះ - ចំពោះការដែលគណៈប្រតិភូសង្កេតឃើញ - ស្ថិតក្នុងភាពអវត្តមាននៃវឌ្ឍនភាពចំពោះករណីទាំងនេះ ទាក់ទងនឹងកង្វល់ធ្ងន់ធ្ងរខាងសិទ្ធិមនុស្សដែលមានពីខាងដើម និងដោយសារបន្តមានការធ្លាក់ដុនដាននៃស្ថានភាពនយោបាយនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះ

- <u>កង្វះវឌ្ឍនភាពចំពោះករណីទាំងនេះ និងកង្វល់អំពីការរំលោភធ្ងន់ធ្ងរលើសិទ្ធិមនុស្សដែលមានពីខាងដើម និងដែលអូសបន្លាយពេលយូរ</u>

- គណៈប្រតិភូបានរកឃើញថា មិនមានវឌ្ឍនភាពត្រូវបានធ្វើឡើង ក្នុងការដោះស្រាយករណីណាមួយទាំងនេះទេ។ គណៈប្រតិភូ នឹងរាយការណ៍អំពីការរកឃើញរបស់ខ្លួនលើករណីជាក់លាក់នីមួយៗ នៅក្នុងរបាយការណ៍បេសកកម្មរបស់ខ្លួន បន្ទាប់ពីពិនិត្យឡើងវិញនូវព័ត៌មានលម្អិត និងឯកសារដែលបានផ្តល់ឲ្យលើករណីនីមួយៗ និងបទប្បញ្ញត្តិច្បាប់ទាំងអស់ ដែលកំពុងអនុវត្ត។

- ទោះជាយ៉ាងណាក៏ដោយ គណៈប្រតិភូបានរកឃើញថា ករណីទាំងនេះ និងវិធានការដែលបានចាត់កាលពីពេលថ្មីៗនេះ ប្រឆាំងនឹងគណបក្សប្រឆាំង អនុវត្តតាមលំនាំចាស់មួយនៅកម្ពុជា ដែលគណៈកម្មាធិការ និងក្រុមប្រឹក្សាភិបាល បានប្រកាសដោយខ្លួនឯងម្តងហើយម្តងទៀតក្នុងរយៈពេល២០ ឆ្នាំចុងក្រោយនេះ និងនាំមកនូវកង្វល់ធ្ងន់ធ្ងរអំពីការការពារសិទ្ធិជាមូលដ្ឋានរបស់សមាជិកសភា ដោយមិនគិតពីនិន្នាការនយោបាយរបស់ពួកគេ។ ក្របខណ្ឌច្បាប់ដែលកំពុងអនុវត្តនៅកម្ពុជា ភាពស្របគ្នានៃក្របខណ្ឌច្បាប់នោះជាមួយនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក៏ដូចជាការអនុវត្តមានប្រសិទ្ធភាពនៃក្របខណ្ឌច្បាប់នៅក្នុងការអនុវត្តជាក់ស្តែង គឺជាស្នូលនៃបញ្ហាជាកង្វល់ដែលកើតឡើងដូចខាងក្រោម ដែលបញ្ហាភាគច្រើនបានបន្សល់ទុកដោយគ្មានការដោះស្រាយដោយអាជ្ញាធរកម្ពុជា រហូតដល់ពេលបច្ចុប្បន្ននេះ៖

    - o រំលោភបំពានជាប្រព័ន្ធលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី (ការចោទប្រកាន់ដោយបំពាន និងមិនសមាមាត្រ សំដៅឆ្លើយតបទៅនឹងការបញ្ចេញមតិជាសាធារណៈជំទាស់នឹងទស្សនៈនយោបាយ ដែលនាំទៅរកការជំនុំជម្រះដែលមិនយុត្តិធម៌ ឬដែលបន្សល់ទុកនូវភាពរយីងរយោងជាច្រើនឆ្នាំ ការបង្អាក់ ការហាមឃាត់ ការបង្ក្រាប ឬការប្រើប្រាស់កម្លាំងហួសហេតុ ទៅលើការតវ៉ារបស់គណបក្សប្រឆាំង)។
    - o គុណវិបត្តិធ្ងន់ធ្ងរចំពោះការប្រព្រឹត្តក្នុងដំណើរការនីតិវិធីរបស់តុលាការ ដែលជាញឹកញយ ស្ថិតនៅក្រោមបទដ្ឋានអន្តរជាតិស្តីពីដំណើរការត្រឹមត្រូវតាមនីតិវិធី និងការជំនុំជម្រះក្តីដោយយុត្តិធម៌ ជាពិសេស ទាក់ទងនឹង សិទ្ធិការពារខ្លួន និង

កង្វល់អំពីកង្វះឯករាជភាពនៃអង្គតុលាការ និងការជ្រៀតជ្រែកពីអង្គប្រតិបត្តិ។

០ កង្វះការការពារសិទ្ធិជាមូលដ្ឋានរបស់សមាជិកសភា (ដោយមិនគិតពីនិន្នាការនយោបាយរបស់ពួកគេ) ដោយស្ថាប័នសភាខ្លួនឯងផ្ទាល់ និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ដែលត្រូវស្តែងឲ្យឃើញច្បាស់ជាពិសេសនៅក្នុងនីតិវិធីដ៏យូរអង្វែង និងការអនុវត្តជាក់ស្តែង ដែលអនុញ្ញាតចំពោះការដកអភ័យឯកសិទ្ធិសភា និងដកហូតអាណត្តិសភារបស់សមាជិកគណបក្សប្រឆាំងនៅក្នុងរដ្ឋសភា។

- គណៈប្រតិភូបានរកឃើញថា កង្វល់ដ៏សំខាន់និងយូរអង្វែងទាំងនេះ នៅមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ បើទោះជាបានធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធមួយចំនួននាពេលកន្លងមកថ្មីៗហើយក្តី និងសហភាពអន្តរសភា (IPU) បានផ្តល់នូវជំនួយបច្ចេកទេសម្តងហើយម្តងទៀត ដើម្បីជួយដល់អាជ្ញាធរកម្ពុជា ដើម្បីដោះស្រាយបញ្ហាទាំងនេះក្តី។

- <u>ភាពធ្លាក់ដុនដាបនៃស្ថានភាពនយោបាយ និងស្ថានភាពបច្ចុប្បន្ននៃកិច្ចសន្ទនានយោបាយ</u>

- គណៈប្រតិភូ អាចបញ្ជាក់ថា "វប្បធម៌សន្ទនា" ត្រូវបានលើកពេលជាលើកដំបូងនៅខែសីហា ឆ្នាំ២០១៥ បន្ទាប់ពីមានការចាប់ខ្លួនសមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ ហើយក្រោយមកត្រូវបានផ្អាកភ្លាមៗនៅចុងខែតុលា ឆ្នាំ២០១៥ បន្ទាប់ពីអ្វីដែលអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិបានចាត់ទុកថាជា "ការបង្ក្រាបលើគណបក្សប្រឆាំង" មានវិធានការជាបន្តបន្ទាប់ ត្រូវបានចាត់ទៅលើគណបក្សប្រឆាំង បន្ទាប់ពីមានបាតុកម្មធ្វើឡើងនៅប្រទេសបារាំងប្រឆាំងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចជាផ្លូវការរបស់លោកទៅកាន់ទីក្រុងប៉ារីស ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៥។ អ្នកគាំទ្រលោកនាយករដ្ឋមន្ត្រី និងគណបក្សប្រជាជនកម្ពុជា បានឆ្លើយតបនឹងការប្រឆាំងតវ៉ានៅប្រទេសបារាំង ដោយបានរៀបចំការប្រឆាំងតវ៉ានៅក្នុងទីក្រុងភ្នំពេញ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥ អំពាវនាវឲ្យលាឈប់ពីតំណែងជាបន្ទាន់របស់លោក កឹម សុខា ដែលជាអនុប្រធានគណបក្សសង្គ្រោះជាតិ និងជាអនុប្រធានរដ្ឋសភា។ គណៈប្រតិភូ បានដឹងថា លោកត្រូវបានគំរាមកំហែង ហើយថាលំនៅដ្ឋានរបស់លោក ត្រូវបានក្រុមបាតុករវាយប្រហារ។ នគរបាលត្រូវបានគេអះអាងថា បានខកខានក្នុងការធ្វើអន្តរាគមន៍ បើទោះបីជាបានទូរស័ព្ទហៅម្តងហើយម្តងទៀតឲ្យជួយអន្តរាគមន៍ក្តី។ ក្រោយមកមិនយូរប៉ុន្មាន លោក កឹម សុខា ត្រូវបានដកចេញពីតំណែងជាអនុប្រធានរដ្ឋសភា នៅក្នុងការបោះឆ្នោតមួយ ដែលត្រូវបានគណបក្សប្រឆាំងធ្វើពហិការ។

- គណៈប្រតិភូក៏បានសង្កេតឃើញផងដែរថា ស្ថានភាពនយោបាយ និងសន្តិសុខមានសភាពតានតឹងនៅរាជធានីភ្នំពេញ អំឡុងពេលដំណើរទស្សនកិច្ចរបស់ខ្លួន។ មានពាក្យចចាមអារ៉ាមតតឈប់ឈរដែលថា គណបក្សប្រឆាំងនឹងត្រូវបានវាយប្រហារជាការសងសឹក ប្រសិនបើមានការរៀបចំតវ៉ារបស់គណបក្សប្រឆាំងនៅសហរដ្ឋអាមេរិកក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាន-អាមេរិក ដែលនាយករដ្ឋមន្ត្រីចូលរួមនោះ។ ដោយភ័យខ្លាចកើតមានអំពើហិង្សា លោក កឹម សុខា បានស្នើសុំឲ្យមានវិធានការការពារ ប៉ុន្តែសំណើរបស់លោកនៅតែមិនទាន់មានការឆ្លើយតបនៅឡើយ។ មានការភ័យខ្លាចថា អាចនឹង

កើតមានឧប្បត្តិហេតុម្តងទៀត ដូចកាលពីខែតុលា ឆ្នាំ២០១៥។ ហេតុដូច្នេះហើយ គណៈប្រតិភូ បានលើកឡើងអំពីបញ្ហានេះជាមួយនឹងលោកឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដែលទទួលខុសត្រូវក្នុងការផ្តល់វិធានការការពារគ្រប់គ្រាន់ដល់តំណាងរាស្ត្រគណបក្សប្រឆាំង និងអ្នកនយោបាយ។ លោកឧបនាយករដ្ឋមន្ត្រីបានជម្រាបជូនគណៈប្រតិភូថា លោកទើបតែបានណែនាំមន្ត្រីនគរបាលឲ្យតាមដានពិនិត្យមើលសំណើសុំនោះហើយ និងឲ្យចាត់វិធានការសមស្របទាំងអស់។ លោក កឹមសុខា បានបញ្ជាក់ថា លោកទទួលបានការផ្តល់ជូនតាមការស្នើសុំហើយ ហើយក៏គ្មានការតវ៉ា ឬឧប្បត្តិហេតុបានកើតឡើងជាបន្តបន្ទាប់ដែរ។

- ទោះបីជាមានស្ថានភាពតានតឹងផ្នែកនយោបាយ ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចរបស់ខ្លួនក៏ដោយ ក៏គណៈប្រតិភូបានសម្រេចចិត្តផ្តោតភាគច្រើនលើតម្រូវការឲ្យគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងបន្តកិច្ចសន្ទនានយោបាយជាបន្ទាន់ និងបន្តប្រើក្របខ័ណ្ឌនេះ ដើម្បីដោះស្រាយលើសំណុំរឿងក្តីទាំងឡាយដែលចាំបាច់នាពេលបច្ចុប្បន្ននេះ។ គណៈប្រតិភូ បានលើកទឹកចិត្តដល់គណបក្សកាន់អំណាច និងគណបក្សប្រឆាំង ធ្វើឲ្យដំណើរការឡើងវិញ និងពង្រឹង "វប្បធម៌សន្ទនា" សម្រាប់ការបោះឆ្នោតឆ្នាំ ២០១៧ និង ២០១៨ នាពេលខាងមុខនេះ។ គណៈប្រតិភូបានសង្កេតឃើញថា យន្តការដ៏រឹងមាំមួយសម្រាប់កិច្ចសន្ទនានយោបាយ ជាតម្រូវការទូទៅនៅក្នុងប្រទេសកម្ពុជា ជាពិសេសដើម្បីទប់ស្កាត់ការកើនឡើងនៃជម្លោះនយោបាយ នៅពេលមានភាពតានតឹង និងគំនិតខ្វែងគ្នាខាងនយោបាយ។ បើតាមទស្សនៈរបស់គណៈប្រតិភូនេះ គំនិតមិនស្របគ្នារវាងគណបក្សនយោបាយធំៗទាំងពីរ និងការបញ្ចេញមតិជាបន្តបន្ទាប់របស់គណបក្សទាំងពីរជាសាធារណៈ តាមរយៈសេចក្តីថ្លែងការជាសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម ឬការរៀបចំធ្វើការតវ៉ា មិនគួរនាំឲ្យមានវិបត្តិនយោបាយជាថ្មីជាលក្ខណៈប្រព័ន្ធ ឡើយ។ យន្តការកាន់តែរឹងមាំ និងមានប្រសិទ្ធភាព អាចនឹងរួមចំណែកដល់ការបង្កើតឱកាសបន្ថែមទៀតសម្រាប់ការជជែកពិភាក្សានយោបាយជាទូទៅប្រកបដោយន័យស្ថាបនា។ ការជជែកពិភាក្សានេះ គួរត្រូវតែធ្វើឡើងដោយមានការរាប់បញ្ចូល តម្លាភាព និងលក្ខណៈស្ថាបនា។ ការជជែកពិភាក្សានេះ ក៏នឹងបង្ការភាគីទាំងពីរមិនឲ្យត្រឡប់ទៅរកទម្លាប់អនុវត្តចាស់នៃការចេញសេចក្តីថ្លែងការណ៍តាមប្រព័ន្ធផ្សព្វផ្សាយ ដោយចោទប្រកាន់គ្នាទៅវិញទៅមក និងមិនឲ្យផ្តួចផ្តើមធ្វើការឆ្លើយតបតាមប្រព័ន្ធតុលាការដែលមានលក្ខណៈជាការបង្ក្រាបផងដែរ។

- <u>ជំហរទូទៅរបស់អាជ្ញាធរកម្ពុជា</u>

- អាជ្ញាធរកម្ពុជាបានបញ្ជាក់ជាថ្មីថា ពួកគេចាត់ទុកថាមិនមានការរំលោភបំពានសិទ្ធិមនុស្សនៅក្នុងសំណុំរឿងក្តីទាំងនោះ នាពេលបច្ចុប្បន្ននេះទេ។ អាជ្ញាធរទាំងនោះបានបញ្ជាក់យ៉ាងច្បាស់ពីទស្សនៈរបស់ខ្លួនថា សាមីតំណាងរាស្ត្រទាំងនោះជាប់ពិរុទ្ធពីបទល្មើសនានាដែលកំពុងបន្តដំណើរការក្តីនៅឡើយ ដូច្នេះហើយ ពួកគេគួរប្រឈមនឹងលទ្ធផលនៃទង្វើរបស់ខ្លួន អនុលោមតាមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា និងដើម្បីការពារនីតិរដ្ឋនៅកម្ពុជា

ផងដែរ។ អាជ្ញាធរកម្ពុជា បានសម្តែងនូវទស្សនៈយ៉ាងខ្លាំងក្លាបន្ថែមទៀតថា ចំណាត់ការផ្លូវច្បាប់ដែលមានលក្ខណៈជាការបង្ក្រាបនេះ ត្រូវធ្វើឡើងជាចាំបាច់ ដើម្បីរក្សាសន្តិភាព និងស្ថិរភាពនៅក្នុងប្រទេសកម្ពុជា ដែលពាក្យសម្តីទាំងនេះត្រូវបានគេនិយាយ សរសេរ ឬបង្ហោះនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ដែលនៅក្នុងទស្សនៈរបស់គេ អាចធ្វើឲ្យខូចសណ្តាប់ធ្នាប់ ឬញុះញង់ឲ្យមានភាពចលាចលក្នុងសង្គម។ មានការនិយាយយោងជាទូទៅដល់សង្គ្រាមស៊ីវិល ដើម្បីធ្វើយុត្តិកម្មចំពោះជំហរនេះ ជាពិសេសពាក់ព័ន្ធទៅនឹងការបោះឆ្នោតនាពេលខាងមុខ និងតម្រូវការដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ច។

- យោងតាមអាជ្ញាធរទាំងនោះ នីតិវិធីតុលាការត្រូវបានដំណើរការហើយ ហើយវាអាស្រ័យលើ តុលាការក្នុងការដោះស្រាយសំណុំរឿងក្តីទាំងនេះ អនុលោមតាមច្បាប់កម្ពុជា។ រដ្ឋសភា និងអង្គនីតិប្រតិបត្តិបានអះអាងថា ការដោះស្រាយសំណុំរឿងក្តីទាំងនេះ គឺជាបញ្ហាតុលាការសុទ្ធសាធ។ អាជ្ញាធរទាំងនោះបានចាត់ទុកថា ពួកគេមិនអាចជ្រៀតជ្រែកបានឡើយ ដោយអនុលោមតាមគោលការណ៍នៃការបែងចែកអំណាច និងឯករាជភាពរបស់តុលាការ។

- អាជ្ញាធរកម្ពុជាក៏បានថ្លែងផងដែរថា ពួកគេមានការលំបាកក្នុងការប្រមើលថាសំណុំរឿងទាំងនេះអាចនឹងត្រូវដោះស្រាយជាផ្នែកមួយនៃវប្បធម៌ការសន្ទនា ដោយរបៀបណា ដោយហេតុថា ពួកគេមិនបានគិតថា ពួកគេមានទំនួលខុសត្រូវលើបញ្ហានយោបាយដើម្បីផលប្រយោជន៍ជាតិ ដែលបានគ្របដណ្តប់ដោយកិច្ចព្រមព្រៀងខែកក្កដា ឆ្នាំ ២០១៤ រវាងគណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិឡើយ។ ពួកគេបានអះអាងថា ដំណោះស្រាយនយោបាយមិនអាចធ្វើទៅបានឡើយ ដោយសារដំណោះស្រាយទាំងនេះរំលោភបំពានរដ្ឋធម្មនុញ្ញប្រទេសកម្ពុជា។ ជាងនេះទៅទៀតអាជ្ញាធរ ទាំងនោះបានអះអាងជាថ្មីថា ពួកគេគាំទ្រដល់ការបន្តនូវកិច្ចសន្ទនានយោបាយ និងមានជំនឿថាកិច្ចសន្ទនានយោបាយនេះជាដំណើរការសំខាន់ ទោះបីជាមានផលលំបាកក្តី។

- អាជ្ញាធរកម្ពុជា ជាពិសេសអាជ្ញាធររដ្ឋសភា ទទួលស្គាល់ថាច្បាប់ និងបទបញ្ញត្តិនានាដែលមានជាធរមាន អាចនឹងត្រូវពិនិត្យ និងធ្វើឲ្យប្រសើរឡើងបន្ថែមទៀត ល្គឹកណាច្បាប់ និងបទបញ្ញត្តិទាំងនោះផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជា។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់រដ្ឋសភា និងព្រឹទ្ធសភា បានសម្តែងនូវចំណាប់អារម្មណ៍ជាពិសេសក្នុងការរៀនសូត្របន្ថែមទៀតពីបទពិសោធន៍របស់បណ្តាប្រទេស និងសភាផ្សេងទៀតអំពីបទដ្ឋានអន្តរជាតិដែលពាក់ព័ន្ធ។

- គណៈប្រតិភូបានសង្កេតឃើញថា ក្នុងអំឡុងទស្សនកិច្ចនោះ អាជ្ញាធរកម្ពុជាមិនបានសម្តែងនូវឆន្ទៈយ៉ាងច្បាស់ ដើម្បីដោះស្រាយសំណុំរឿងទាំងនេះដែលចាំបាច់ត្រូវធ្វើនាពេលបច្ចុប្បន្ននេះ ឬក៏ព្យាយាមដើម្បីធ្វើឲ្យមានដំណើរការទៅមុខឈានទៅរកដំណោះស្រាយគួរជាទីពេញចិត្តមួយឡើយ

*ដោយយល់ឃើញផងដែរថា* គណៈប្រតិភូបានចាកចេញពីប្រទេសកម្ពុជាដោយមានសុទិដ្ឋិនិយម

មួយចំនួន បន្ទាប់ពីភាគីគណបក្សទាំងពីរបានសម្តែងនូវបំណងរបស់ខ្លួនក្នុងការបន្តកិច្ចសន្ទនានយោបាយ ហើយលោកឧបនាយករដ្ឋមន្ត្រីបានសន្យាថានឹងជួបជាមួយគណបក្សសង្គ្រោះជាតិដើម្បីសម្រេចគោលដៅនោះ, *ដោយយល់ឃើញថា* ពិតជាមានកិច្ចប្រជុំមួយ បានធ្វើឡើងនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៦ បើទោះជាសំណុំរឿងទាំងនោះដែលចាំបាច់ត្រូវដោះស្រាយនាពេលនេះ និងដំណោះស្រាយរបស់គណៈបក្សទាំងពីរនៅមិនទាន់បានពិភាក្សានៅឡើយ, *ដោយយល់ឃើញថា* បើទោះបីជា គ្មានការជួបប្រជុំរវាងគណបក្សកាន់អំណាច និងគណបក្សប្រឆាំង បន្ទាប់ពីមានការសន្យាថានឹងជួបប្រជុំ ហើយកិច្ចសន្ទនានយោបាយនៅតែជាប់គាំងរហូតដល់ពេលបច្ចុប្បន្ននេះ ក៏ដោយ។

*ដោយយល់ឃើញ*ថា អាជ្ញាធរកម្ពុជាមិនបានចែករំលែកជាបន្តបន្ទាប់នូវព័ត៌មានណាមួយ ឬ ឆ្លើយតបទៅនឹងសំណើសុំព័ត៌មានបច្ចុប្បន្នភាព តាំងពីពេលដំណើរទស្សនកិច្ចមក, *ដោយយល់ឃើញថា* បើយោងតាមព័ត៌មាននាពេលថ្មីៗនេះ ដែលបានចែករំលែកដោយអ្នកដាក់បណ្តឹង និងភាគីទីបី មិនឃើញមានវឌ្ឍនភាពបន្ថែមទៀត លើករណីសំណុំរឿងទាំងនេះឡើយ តែផ្ទុយទៅវិញ ៖ (១) កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ ២០១៦ តុលាការបានបដិសេធបណ្តឹងឧទ្ធរណ៍កាលពីពេលថ្មីៗនេះរបស់សមាជិកព្រឹទ្ធសភាលោក ហុង សុខហួរ ប្រឆាំងនឹងការឃុំខ្លួនលោកបណ្តោះអាសន្នដែលបន្តមកជាយូរមកហើយរបស់លោក ហើយ តុលាការមិនបានដោះស្រាយបញ្ហាសុខភាព និងកង្វល់នានាដែលបានលើកឡើងដោយសមាជិកព្រឹទ្ធសភារូបនេះ ទាក់ទងនឹងសុខភាពរបស់លោកឡើយ ពោលគឺតុលាកាបានបដិសេធមិនព្រមដោះលែងលោកឲ្យនៅក្រៅឃុំ ដោយឈរលើហេតុផលថា វាអាចនឹងបង្កើតឲ្យមានភាពចលាចល និង ខូចសណ្តាប់ធ្នាប់សង្គម និង (២) មានបទចោទប្រកាន់ជាបន្តបន្ទាប់ប្រឆាំងនឹង លោក សម រង្ស៊ី កាលពីដើមខែមីនា ឆ្នាំ ២០១៦។

*ដោយចងចាំក្នុងចិត្ត*នូវការពោលអះអាងខាងក្រោមទាក់ទងនឹងកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជាក្នុងការគោរព ការពារ និងលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន៖

- ក្នុងនាមជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កម្ពុជាមានកាតព្វកិច្ចគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងសិទ្ធិជាមូលដ្ឋានចំពោះសេរីភាពនៃការបញ្ចេញមតិ សេរីភាពការជួបប្រជុំ ភាពស្មើគ្នាចំពោះមុខច្បាប់ និងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដែលធ្វើឡើងដោយតុលាការមួយដែលឯករាជ្យ និងមិនលំអៀង។

- បន្ទាប់ពីវដ្តទី២នៃការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) របស់ប្រទេសកម្ពុជា ដែលបានធ្វើឡើងដោយក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅឆ្នាំ២០១៤ អាជ្ញាធរកម្ពុជាបានទទួលយកអនុសាសន៍ដើម្បី "ធ្វើឲ្យប្រសើរឡើងនូវបរិស្ថានសុវត្ថិភាព និងអំណោយផលដែលអនុញ្ញាតឲ្យបុគ្គលនានា និងក្រុមទាំងឡាយ អាចអនុវត្តសេរីភាពនៃការបញ្ចេញមតិ សេរីភាពបង្កើតសមាគម និងសេរីភាពជួបប្រជុំដោយសន្តិវិធី និងបញ្ឈប់ការរុកគួន ការគំរាមកំហែង ការចាប់ខ្លួនតាមអំពើចិត្ត និងការវាយប្រហារលើរាងកាយ ជាពិសេសក្នុងបរិបទនៃការធ្វើបាតុកម្មដោយសន្តិវិធី" និង "ចាត់វិធានការចាំបាច់ទាំងអស់ដើម្បីធានាឲ្យបាននូវឯករាជភាពវិស័យយុត្តិធម៌ដោយមិនមានការគ្រប់គ្រង ឬជ្រៀតជ្រែកផ្នែកនយោបាយ" (របាយការណ៍របស់ក្រុមការងារ UPR នៃប្រទេសកម្ពុជា A/HRC/26/16)។

- អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា បានសង្កេតឃើញថា បន្ទាប់ពីដំណើរទស្សនកិច្ចរបស់លោកស្រី មកកាន់ប្រទេសកម្ពុជានៅខែកញ្ញា ឆ្នាំ២០១៥ និងនៅក្នុងរបាយការណ៍ផ្ទាល់មាត់របស់លោកស្រី ថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៥ មក មានការមូលមតិគ្នាជាទូទៅក្នុងចំណោមតួអង្គសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាថា លំហសម្រាប់អនុវត្តសេរីភាពទាំងនេះដោយសន្តិភាពបានរួមតូចហើយ ខណៈពេលដែលប្រទេសនេះបានធ្វើដំណើរឆ្ពោះទៅការបោះឆ្នោតឃុំ/សង្កាត់ ក្នុងឆ្នាំ២០១៧ និងការបោះឆ្នោតសភាជាតិឆ្នាំ ២០១៨។ លោកស្រីបានចង្អុលបង្ហាញថា ក្នុងអំឡុងពេលបេសកកម្មរបស់លោកស្រី លោកស្រីបានកត់សម្គាល់ឃើញថា មានការបកស្រាយផ្ទុយដាច់ស្រឡះនូវការរឹតត្បិតដែលអនុញ្ញាតដោយច្បាប់លើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ សិទ្ធិសេរីភាពជួបប្រជុំ និងសិទ្ធិសេរីភាពបង្កើតសមាគម ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបានក្រើនរំឭកថាតុល្យភាពរវាងការការពារសេរីភាពទាំងនេះ និងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ចំបាច់ត្រូវកំណត់យកដោយសមស្រប និងអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលទាំងនេះជាអ្វីដែលលោកស្រី បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងអំឡុងអាណត្តិរបស់លោកស្រី។

*ដោយចងចាំក្នុងចិត្តផងដែរ* ជំពូក ៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីសិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ពិសេស មាត្រា ៣១ ដែលចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស (។)" ព្រមទាំងមាត្រា ៨០ និង មាត្រា ១០៤ ដែលចែងថា "សមាជិកសភា និងសមាជិកព្រឹទ្ធសភាមានអភ័យឯកសិទ្ធិសភា និងចែងថា "តំណាងរាស្ត្ររូបណាក៏ដោយ មិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសម្តែងមតិ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ"។

១. *សូមថ្លែងអរគុណដល់*អាជ្ញាធរកម្ពុជាដែលបានទទួលដំណើរទស្សនកិច្ចនេះ និងជួយជ្រោមជ្រែងដល់គណៈប្រតិភូ។ *ដោយយល់ឃើញថា* ការបំពេញទស្សនកិច្ច និងកិច្ចពិភាក្សានានា គឺជាជំហានវិជ្ជមានដំបូង តែទោះជាយ៉ាងនេះក៏ដោយ *ក៏មានការសោកស្តាយ*ដែលមិនមានព័ត៌មានបន្តបន្ទាប់ចែករំលែកដោយអាជ្ញាធរចាប់តាំងពីដំណើរទស្សនកិច្ចនោះមកនៅឡើយទេ

២. *កត់សម្គាល់*នូវការសង្កេតបឋមរបស់គណៈកម្មាធិការស្តីពីទស្សនកិច្ចនេះ និងរង់ចាំដោយអន្ទះសានូវរបាយការណ៍ចុងក្រោយនៃបេសកកម្ម នៅសន្និបាតសហភាពអន្តរសភា (ខែតុលា ឆ្នាំ ២០១៦)

៣. *កត់សម្គាល់*ដោយមានការសោកស្តាយយ៉ាងជ្រាលជ្រៅថា មិនត្រឹមតែមិនមានវឌ្ឍនភាពក្នុងការដោះស្រាយករណីសំណុំរឿងទាំងឡាយរបស់សមាជិកសភាគណបក្សប្រឆាំងទាំង១២ រូប ប៉ុណ្ណោះទេ ថែមទាំងស្ថានភាពរបស់សមាជិកសភាមួយចំនួន បានធ្លាក់ដុនដាបបន្ថែមទៀតនាពេលបច្ចុប្បន្ននេះ ដូចបានឃើញស្ថានភាពនយោបាយទូទៅនៅក្នុងប្រទេសកម្ពុជា បានធ្វើឲ្យមានការអាក់ខានដល់វប្បធម៌សន្ទនា ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៥ ថែមទៀត

៤. *បង្ហាញនូវកង្វល់យ៉ាងខ្លាំងលើ*បញ្ហាសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរកើតចេញពីករណីសំណុំរឿងទាំងនេះ និង*សូមជម្រុញឲ្យ*អាជ្ញាធរកម្ពុជា ព្រមទាំងតួអង្គ នយោបាយទាំងអស់នៅក្នុងប្រទេសកម្ពុជា ស្វែងរកដំណោះស្រាយរយៈពេលវែងចំពោះបញ្ហាទាំងនេះជាបន្ទាន់ដើម្បីបញ្ចប់នូវការកើតឡើងសាជាថ្មីជាបន្តបន្ទាប់នូវករណីស្រដៀងគ្នានេះនាពេលអនាគត គឺមិនត្រឹមតែដើម្បីផលប្រយោជន៍ស្ថាប័នសភា និងសមាជិកសភាសភាមួយរូបៗ ប៉ុណ្ណោះទេ ថែមទាំងដើម្បីផលប្រយោជន៍សំខាន់បំផុតរបស់ប្រជាជាតិកម្ពុជាទាំងមូល ផងដែរ *ជឿជាក់បន្ថែមទៀតថា* មានតែដំណោះស្រាយរយៈពេលវែងប៉ុណ្ណោះដែលអាចមានចីរភាព និងប្រសិទ្ធភាពប្រសិនបើដំណោះស្រាយទាំងនោះ អនុលោមតាមយ៉ាងខ្ជាប់ខ្ជួនទៅនឹងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងទម្លាប់អនុវត្តល្អប្រពៃនានាដែលមានជាធរមាននៅក្នុងសភាធិបតេយ្យ

៥. សូមអំពាវនាវដល់គ្រប់ស្ថាប័នអំណាច និងគណៈបក្សនយោបាយទាំងអស់ រួមដៃគ្នាធ្វើការដើម្បីធានាថា៖

(១) មានការគោរពពេញលេញនូវអភ័យឯកសិទ្ធិសភា និងអាណត្តិសភា ដែលប្រជាពលរដ្ឋកម្ពុជាបានប្រគល់ដល់សមាជិកសភា ព្រមទាំងសិទ្ធិសេរីភាពរបស់សភាទាំងនោះក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី សិទ្ធិទទួលបានប្រព័ន្ធតុលាការឯករាជ្យ និងកិច្ចដំណើរការនីតិវិធីតុលាការប្រកបដោយយុត្តិធម៌ រាប់ទាំងច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនានា ត្រូវអនុលោមតាមបទដ្ឋានអន្តរជាតិ និងទម្លាប់អនុវត្តន៍របស់សភាប្រជាធិបតេយ្យ

(២) ជនដែលបានញុះញង់ និងធ្វើការវាយប្រហារ គំរាមកំហែង និងបំភិតបំភ័យតំណាងរាស្ត្រ ត្រូវទទួលខុសត្រូវ ហើយនាពេលអនាគត អាជ្ញាធរពាក់ព័ន្ធត្រូវផ្តល់វិធានការការពារជាប្រព័ន្ធឲ្យបានឆាប់ និងមានប្រសិទ្ធភាព នៅពេលណាដែលសមាជិកសភាយល់ថាមានការទទួលរងការគំរាមកំហែង

(៣) ដំណើរការនីតិវិធីរបស់តុលាការជាបន្តប្រឆាំងនឹងសមាជិកសភាទាំងនោះបានបញ្ចប់ដោយមិនមានការពន្យាពេលដោយមិនសមរម្យ ប្រកបដោយយុត្តិធម៌ ឯករាជ្យ មិនលំអៀង និងតម្លាភាព រាប់ទាំង - ខណៈពេលដែលត្រូវបានធានាដោយភ័ស្តុតាងដោះបន្ទុក និងស្ថានសម្រាលទោស - តាមរយៈសេចក្តីសម្រេចទម្លាក់ចោល ការចោទប្រកាន់ ឬ ដូរបទចោទប្រកាន់ បញ្ឈប់កិច្ចដំណើរការនីតិវិធី ឬ លើកលែងការចោទប្រកាន់ជនសង្ស័យ ដោយស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនានានៃក្រមនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ដែលតម្រូវឲ្យគោរពគោលការណ៍សច្ចធារណ៍នៃនិរទេស និងសិទ្ធិរបស់ជនជាប់ចោទ

៦. *យល់ឃើញ*ថា វាជាការសំខាន់ណាស់ដែលគណបក្សកាន់អំណាច និងគណបក្សប្រឆាំងបន្តកិច្ចសន្ទនានយោបាយ សំដៅកសាងបរិស្ថាននយោបាយមួយប្រកបដោយស្ថេរភាពដែលមានលំហគ្រប់គ្រាន់សម្រាប់មតិមិនយល់ស្រប និងការអនុវត្តដោយសន្តិវិធីនូវសេរីភាពបញ្ចេញមតិ សេរីភាពបង្កើតសមាគម និងសេរីភាពជួបប្រជុំដោយសន្តិវិធី ក្នុងបរិបទនៃការបោះឆ្នោត ដែលនឹងខិតជិតមកដល់យ៉ាងលឿននេះ។ *ជឿជាក់បន្ថែមទៀត*ថា ការ

បន្តនូវកិច្ចសន្ទនានយោបាយ នឹងជួយឲ្យភាគីទាំងពីរស្វែងរកបាននូវដំណោះស្រាយដោយពេញចិត្តចំពោះករណីសំណុំរឿងទាំងនេះដែលចាំបាច់ត្រូវដោះស្រាយនាពេលបច្ចុប្បន្ន

៧. *វាយតម្លៃខ្ពស់*នូវកិច្ចប្រឹងប្រែងរបស់សភាកម្ពុជាថាជាផ្នែកមួយនៃវប្បធម៌សន្ទនា។ *ជឿជាក់ដោយស្មោះ*ថា ស្ថាប័នសភាមានកាតព្វកិច្ចពិសេសក្នុងការលើកកម្ពស់សិទ្ធិរបស់សមាជិករបស់ខ្លួនទាំងអស់ដោយមិនគិតពីនិន្នាការនយោបាយរបស់ពួកគេ និងដើម្បីធានាថាសិទ្ធិទាំងនេះត្រូវបានលើកកម្ពស់យ៉ាងត្រឹមត្រូវ ដោយអង្គនីតិប្រតិបត្តិ និងតុលាការ គ្រប់ពេលវេលាផងដែរ។ *លើកទឹកចិត្តឲ្យ*សភាកម្ពុជាដើរតួនាទីឲ្យកាន់តែសកម្ម ក្នុងការជម្រុញឲ្យមានដំណោះស្រាយគួជាទីពេញចិត្តនៅក្នុងករណីសំណុំរឿងទាំងនេះដែលចាំបាច់ត្រូវដោះស្រាយនាពេលបច្ចុប្បន្ន និងក្នុងការពង្រឹងការការពារសិទ្ធិជាមូលដ្ឋានរបស់សមាជិករបស់ខ្លួននាពេលអនាគត។

៨. *សូមបន្តឡើងវិញ*នូវការផ្តល់ជំនួយបច្ចេកទេសរបស់ខ្លួនដើម្បីជួយដល់សភាកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធដទៃទៀត ក្នុងការដោះស្រាយបញ្ហាកង្វល់ខាងលើ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យសភា និងនីតិរដ្ឋនៅកម្ពុជា។ *សូមបន្តឲ្យយើងបានដឹង*អំពីចម្លើយតបរបស់សភាកម្ពុជា ព្រមទាំងដំណើរវិវឌ្ឍទាំងឡាយនាពេលខាងមុខ ដែលមានជាប់ពាក់ព័ន្ធនឹងករណីសំណុំរឿងរបស់តំណាងរាស្ត្រគណបក្សប្រឆាំងទាំង១២ រូប ដែលកំពុងស្ថិតក្នុងការពិនិត្យរបស់តុលាការ។

៩. *ស្នើឲ្យ*អគ្គលេខាធិការពាំនាំនូវសេចក្តីសម្រេចនេះឲ្យបានដឹងដល់អាជ្ញាធរមានសមត្ថកិច្ចអ្នកប្តឹងតវ៉ា និងភាគីទីបីណាមួយ ដែលអាចមានតួនាទីក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនានា

១០. *ស្នើឲ្យ*គណៈកម្មាធិការបន្តពិនិត្យមើលករណីសំណុំរឿងទាំងនេះ និងរាយការណ៍ត្រឡប់វិញ តាមពេលវេលាសមស្រប។

ចប់